**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៥៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងពង្រឹងតួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការពារធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានានៅទូទាំងប្រទេស។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវសមាសភាព តួនាទី ភារកិច្ច សិទ្ធិអំណាច និងរបៀបរបបការងាររបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ។

**មាត្រា ៤.-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានសមាសភាពដូចខាងក្រោម៖

ក. **គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត៖**

| | | |
|---|---|---|
| ១. | អភិបាលរាជធានី ខេត្ត | ជាប្រធាន |
| ២. | មេបញ្ជាការ ឬមេបញ្ជាការរងយោធភូមិភាគដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត | ជាអនុប្រធាន |
| ៣. | អភិបាលរងរាជធានី ខេត្ត០១រូប | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៤. | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាអនុប្រធាន |
| ៥. | ស្នងការនគរបាលរាជធានី ខេត្ត | ជាអនុប្រធាន |
| ៦. | មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | ជាអនុប្រធាន |
| ៧. | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | ជាសមាជិក |
| ៨. | ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត | ជាសមាជិក |
| ៩. | ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត | ជាសមាជិក |
| ១០. | ប្រធានសាខាគយ និងរដ្ឋាកររាជធានី ខេត្ត | ជាសមាជិក |
| ១១. | ប្រធានសាខាពន្ធដាររាជធានី ខេត្ត | ជាសមាជិក |
| ១២. | នាយករដ្ឋបាលសាលារាជធានី ខេត្ត | ជាសមាជិក |

១៣. ប្រធានខណ្ឌរដ្ឋបាលព្រៃឈើដែលប្រតិបត្តិការ ក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ជាសមាជិក

១៤. ប្រធានខណ្ឌរដ្ឋបាលជលផលដែលប្រតិបត្តិការក្នុងដែន សមត្ថកិច្ចរបស់រាជធានី ខេត្ត ជាសមាជិក

១៥. នាយកឧទ្យានុរក្សដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ច របស់រាជធានី ខេត្ត ជាសមាជិក

១៦. អភិបាលក្រុង ស្រុក ខណ្ឌ ជាសមាជិក

ខ. គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ៖

១. អភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន

២. អភិបាលរងក្រុង ស្រុក ខណ្ឌ០១រូប ជាអនុប្រធានអចិន្ត្រៃយ៍

៣. មេបញ្ជាការផ្នែកប្រតិបត្តិការសឹករងក្រុង ស្រុក ឬប្រធានក្រុម យោធភូមិភាគពិសេសប្រចាំខណ្ឌ ជាអនុប្រធាន

៤. អធិការនគរបាលក្រុង ស្រុក ខណ្ឌ ជាអនុប្រធាន

៥. មេបញ្ជាការកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ជាអនុប្រធាន

៦. នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ជាសមាជិក

៧. ប្រធានការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ជាសមាជិក

៨. ប្រធានការិយាល័យបរិស្ថានក្រុង ស្រុក ខណ្ឌ ជាសមាជិក

៩. ប្រធានផ្នែករដ្ឋបាលព្រៃឈើដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ច របស់ក្រុង ស្រុក ខណ្ឌ ជាសមាជិក

១០. ប្រធានផ្នែករដ្ឋបាលជលផលដែលប្រតិបត្តិការក្នុងដែនសមត្ថកិច្ច ក្រុង ស្រុក ខណ្ឌ ជាសមាជិក

១១. មេឃុំ ចៅសង្កាត់ ជាសមាជិក

ក្រៅពីសមាសភាពដូចបានកំណត់ខាងលើ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាចបន្ថែមនូវប្រធានមន្ទីរ អង្គភាពខ្សែបណ្តោយនៃក្រសួង ស្ថាប័នដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗជាសមាជិកនៃគណៈបញ្ជាការឯកភាពរបស់ខ្លួនស្របតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ។

**មាត្រា ៥.-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានតួនាទី និងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងចាត់វិធានការស្របតាមគោលការណ៍ច្បាប់ ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសដែលពាក់ព័ន្ធនឹងអំពើភេរវកម្ម អំពើលួច ឆក់ប្លន់គ្រប់ប្រភេទ ការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ អំពើហឹង្សាគ្រប់ប្រភេទ ក្មេងទំនើង ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ អំពើបំផ្លិចបំផ្លាញធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ និងបទល្មើសគ្រប់ប្រភេទផ្សេងទៀតដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដោះស្រាយឲ្យបានទាន់ពេលវេលានូវបាតុភាពនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការបំផ្លិចបំផ្លាញធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ និងបទល្មើសនានាដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ សម្របសម្រួល និងចាត់ចែងការងារដើម្បីឆ្លើយតបទៅនឹងស្ថានភាពចាំបាច់នៃការកិច្ចយោធា សន្តិសុខនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ ត្រួតពិនិត្យការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- បំផុស និងលើកកម្ពស់ការចូលរួមពីមន្ទីរ អង្គភាព និងសហគមន៍មូលដ្ឋានក្នុងការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- លើកកម្ពស់កិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភូមិសាស្ត្រជាប់គ្នា ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានាដែលមានការពាក់ព័ន្ធក្នុងភូមិសាស្ត្ររួម។

**មាត្រា ៦.-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានសិទ្ធិអំណាច និងរបៀបរបបការងារដូចខាងក្រោម៖

- ក្នុងការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ បញ្ជាកងកម្លាំង អាជ្ញាធរមានសមត្ថកិច្ច មន្ទីរ អង្គភាពពាក់ព័ន្ធនានា រួមបញ្ចូលទាំងខណ្ឌ ផ្នែករដ្ឋបាលព្រៃឈើ ខណ្ឌ ផ្នែករដ្ឋបាលជលផល និងឧទ្យានុរក្សតំបន់ការពារធម្មជាតិ ដើម្បីចាត់វិធានការស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ ក្នុងករណីចាំបាច់ គណៈបញ្ជាការឯកភាពអាចសម្របសម្រួល ប្រមូលផ្តុំកម្លាំងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនធ្វើអន្តរាគមន៍ ឬអាចរាយការណ៍ ស្នើសុំអន្តរាគមន៍ពីថ្នាក់ជាតិ ក្នុងករណីដែលគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត មិនអាចដោះស្រាយបាន

- សមាជិកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវចូលរួមប្រជុំ និងអនុវត្តការងារតាមការអញ្ជើញ និងតាមការណែនាំរបស់ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី
- ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាចអញ្ជើញប្រធានមន្ទីរ អង្គភាព ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឲ្យចូលរួមកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់
- ក្នុងករណីចាំបាច់ដែលតម្រូវឲ្យមានការជានានូវការសម្ងាត់ក្នុងកិច្ចការយោធា និងសន្តិសុខ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានសិទ្ធិកោះប្រជុំដោយអញ្ជើញសមាជិកដែលពាក់ព័ន្ធកិច្ចការយោធា និងសន្តិសុខឲ្យចូលរួមតែប៉ុណ្ណោះ
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនជូនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី
- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរាយការណ៍ជាប្រចាំអំពីការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនជូនទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តសាមី
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តត្រូវរាយការណ៍ សុំយោបល់ដឹកនាំជាប្រចាំអំពីការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនពីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ
- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំអំពីការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តសាមី។ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តត្រូវបូកសរុបធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចកោះប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា ៧.-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវរៀបចំឲ្យមានលេខាធិការដ្ឋានដើម្បីជួយការងារក្នុងគណៈបញ្ជាការឯកភាពរបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

អនុក្រឹត្យលេខ២២ អនក្រ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតគណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក ខណ្ឌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន**សម្តេចអគ្គមហាសេនាបតីតេជោ**

**នាយករដ្ឋមន្ត្រី**សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>កន្លែងទទួល</u> ÷**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*